# មេរៀនទី៧០៖ ព្រះយេស៊ូវយាងចូលទីក្រុងយេរូសាឡឹម

## ម៉ាកុស ១១៖ ១- ១១

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/J3oBnGS41zA

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/sm_Ra5igl_o

**គោលបំណង៖** ព្រះយេស៊ូវគឺជាស្តេចរបស់យើងទាំងអស់គ្នា។

**ខគម្ពីរចងចាំ៖** វិវរណៈ ១៩៖១៦ *"ទ្រង់មានព្រះនាមកត់នៅព្រះពស្ត្រ ហើយនៅព្រះឧរូទ្រង់ថា «ស្តេចលើអស់ ទាំងស្តេច ជាព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់»"។*

**ចំរៀង** ( *យូធូបលីង* )៖
១.ស្តេចលើស្តេច https://youtu.be/CPBqHYVwm3M
២.ហូសាណា https://youtu.be/QWQ47zCVaCw
៣.ព្រះយេស៊ូវគឺជាព្រះម្ចាស់ https://youtu.be/I-PzUIJ0MVo

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត «ស្តេច ម្ចាស់ក្សត្រី អ្នកបំរើ »**

១. ឲ្យកុមារចាប់ដៃគូរពីរៗនាក់ (ប្រុសគូរប្រុស ស្រីគូរស្រី)

២. នៅពេលដែលគ្រូ ស្រែកថា "ស្តេច" ដៃគូត្រូវសម្រេចចិត្តឲ្យបានលឿន ថាអ្នកណាត្រូវដើរតួជាស្តេច អ្នកណាត្រូវដើរតួជាអ្នកបំរើ។ អ្នកបំរើត្រូវលុតជង្គង់ចុះ ស្តេចត្រូវអង្គុយនៅលើខ្នងរបស់អ្នកបំរើនោះ។

៣. នៅពេលដែលឮពាក្យថា "ម្ចាស់ក្សត្រី" អ្នកបំរើត្រូវលុតជង្គង់ចុះ ម្ចាស់ក្សត្រីត្រូវដាក់ជង្គង់លើខ្នងរបស់ អ្នកបំរើនោះ។

៤. នៅពេលដែលឮពាក្យថា "អ្នកបំរើ" ពួកគេត្រូវអៀវគ្នា នរណាជាអ្នកអៀវក៏បាន។

៥. ក្រុមដែលមិនធ្វើតាមការណែនាំនិងចាញ់ល្បែងនេះ។

**៤. ការណែនាំមេរៀន**

ការសំដែងខ្លី(គ្រូសូមត្រៀមធាងដូងមុនពេលសិស្សមកដល់ថ្នាក់រៀន)៖ ឲ្យកុមារដោះអាវរបស់ ពួកគេក្រាលតំរៀបគ្នាដូចជាផ្លូវ ហើយកុមារឈរជា២ជួរ នៅអមសងខាងបានដាក់អាវក្រាលនោះ ហើយ ឲ្យកុមារទាំងអស់កាន់ ធាងដូងតូចម្នាក់១ធាង ហើយស្រែកថា ហូសាណាៗ។

មុនពេលការសុគត និងការមានព្រះជន្មរស់ឡើងវិញ របស់ព្រះយេស៊ូវមួយអាទិត្យ ព្រះអង្គបានយាងចូលទៅទីក្រុងយេរូសាឡិម។ ព្រះយេស៊ូវបានជិះលើខ្នងសត្វលាដើម្បីចូលទៅទីក្រុងយេរូសាឡិម មនុស្សម្នាទទួលស្គាល់ថា ព្រះយេស៊ូវជាព្រះមេស្ស៊ីព្រមទាំងស្រែកសរសើរដំកើងទ្រង់ផង។ យើងហៅការនេះថាអាទិត្យស្លឹកចាក។ ថ្ងៃនេះយើងនឹងរៀនពី ក្តីអំណររបស់ប្រជាជនទាំងអស់ ខណៈពេលដែលព្រះយេស៊ូវយាងចូលទីក្រុងយេរូសាឡឹម។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ថ្ងៃមួយ ព្រះយេស៊ូវ និងសិស្សរបស់ទ្រង់បានដើរទៅទីក្រុងយេរូសាឡឹម។ មុនពេលពួកគេបានចូលដល់ទីក្រុងយេរូសាឡឹមបន្តិច ព្រះយេស៊ូវបានមានបន្ទូលទៅកាន់សិស្សរបស់ទ្រង់។ ព្រះអង្គបានបង្ហាញការណែនាំដល់ពួកគេយ៉ាងចំឡែក។ ព្រះគម្ពីរ **ម៉ាកុស ១១៖២-៣** *" ដោយព្រះបន្ទូលថា ចូរទៅ ឯភូមិខាងមុខនុ៎ះ កាលណាចូលទៅដល់ នោះនឹងឃើញកូនលាគេបានចងទុក ដែលឥតមានអ្នកណាទាន់ ជិះនៅឡើយ ចូរស្រាយដឹកនាំវាមក បើអ្នកណាសួរថា ស្រាយវាធ្វើអ្វី នោះត្រូវឆ្លើយថា ព្រះអម្ចាស់ទ្រង់ត្រូវការនឹងវា រួចគេនឹងឲ្យវាមកហើយ"។*

សិស្សរបស់ព្រះយេស៊ូវបានស្ដាប់បង្គាប់ទ្រង់។ អ្នកទាំង២ក៏ចេញទៅក្នុងភូមិ ហើយឃើញកូនលាគេចងទុក ហើយពួកគេក៏ស្រាយវា។ ពេលដែលពួកគេធ្វើតាមការណែនាំរបស់ព្រះយេស៊ូវ មានអ្នកខ្លះដែលឈរនៅទីនោះគេសួរថា អ្នកស្រាយកូនលាធ្វើអី។ ពួកសិស្សទាំងនោះឆ្លើយប្រាប់ថា ព្រះយេស៊ូវត្រូវការសត្វលា។ មនុស្សទាំងនោះ បានយល់ព្រមឲ្យ ព្រះយេស៊ូវអាចយកសត្វលាទៅបាន ដូច្នេះហើយពួកសិស្សក៏បានយក សត្វលានោះទៅថ្វាយព្រះយេស៊ូវ។

ពួកសិស្សបានក្រាលអាវគេនៅលើខ្នងលា ដូច្នេះហើយព្រះយេស៊ូវនឹងអាចអង្គុយលើខ្នងលាបានស្រួល។ ព្រះយេស៊ូវបានឡើងទៅលើខ្នងលា ហើយចាប់ផ្ដើមជិះលាចូលទៅក្នុងទីក្រុង! មនុស្សម្នាជាច្រើនសប្បាយរីករាយខ្លាំងណាស់ ដែលបានឃើញព្រះយេស៊ូវ ហើយពួកគេនាំគ្នាក្រាលអាវខ្លួននៅលើផ្លូវ ហើយខ្លះ ទៀតកាច់មែកឈើយកមករាយតាមផ្លូវដែរ។

ព្រះយេស៊ូវបានជិះសត្វលាពីលើផ្លូវដែលមនុស្សម្នាបានរៀបចំសំរាប់ទ្រង់។ ពេលដែលព្រះយេស៊ូវបានធ្វើដំណើរមក មនុស្សម្នាជាច្រើនដែលដើរពីមុខ និងពីក្រោយព្រះយេស៊ូវបានស្រែកឡើងទាំងអស់គ្នាថា៖
ព្រះគម្ពីរ **ម៉ាកុស ១១៖៩-១០**

"ហូសាណា!"
"ទ្រង់ប្រកបដោយព្រះពរ ព្រះអង្គដែលយាងមក ដោយនូវព្រះនាមព្រះអម្ចាស់!"
"ទ្រង់ប្រកបដោយព្រះពរ រាជ្យនៃហ្លួងដាវីឌ!"
"ហូសាណា នៅស្ថានដ៏ខ្ពស់បំផុត!"

"ហូសាណា" គឺជាពាក្យសរសើរដំកើង និងទូលសុំឲ្យព្រះអង្គ សង្គ្រោះយើង"។ ព្រះយេស៊ូវ គឺជាស្ដេចដ៏ស្វារ្យណាស់ ដូច្នេះមនុស្សម្នាបានសរសើរដំកើងទ្រង់ និងថ្វាយបង្គំព្រះអង្គ។ តើព្រះយេស៊ូវជាស្ដេចដ៏អស្ចារ្យសំរាប់ជីវិតរបស់អ្នកដែលឬទេ? ព្រះយេស៊ូវបាន យាងមករកយើងជាស្ដេចលើសអស់ទាំងស្ដេច! យើងត្រូវការសរសើរ និងថ្វាយបង្គំទ្រង់ ព្រោះទ្រង់ជា ស្ដេចនៃយើង!

## ៦. សំនួរពិភាក្សា

១. តើទីក្រុងដែលព្រះយេស៊ូវយាងចូលជាមួយពួកសិស្សរបស់ទ្រង់មានឈ្មោះអ្វី? *(យេរូសាឡឹម)*

២. តើព្រះយេស៊ូវជិះលើខ្នងសត្វអ្វី? *(សត្វលា)*

៣. តើមនុស្សម្នាបានធ្វើអ្វីខ្លះ? *(យកអាវគេទៅក្រាលលើផ្លូវ និងកាច់មែកឈើយកមករាយតាមផ្លូវដែរ ហើយពួកគេបានស្រែកឡើងថា "ហូសាណា")*

៤. ហេតុអ្វីបានជាមនុស្សម្នាទាំងអស់នោះស្រែកសរសើរដំកើង និងថ្វាយបង្គំព្រះយេស៊ូវ? *(ពួកគេដឹងថាព្រះយេស៊ូវទ្រង់ជាស្ដេច)*

៥. តើព្រះយេស៊ូវជានរណាសំរាប់អ្នក? *(ព្រះយេស៊ូវជាស្តេចរបស់ខ្ញុំ)*

## ៧. ល្បែងកំសាន្ត «វាឲ្យជិះប្រណាំងគ្នា»

១. ឲ្យកុមារចាប់ដៃគូគ្នាពីរៗនាក់ (ប្រុសចាប់ដៃគូប្រុស ស្រីចាប់ដៃគូស្រី)

២. គ្រូត្រូវកំណត់ទីតាំងបញ្ចប់នៅចុងបន្ទប់រៀន ដោយវាឲ្យដៃគូរបស់ពួកគេជិះពីលើខ្នង។

៣. នៅពេលដែលកុមារស្រែក "១ ២ ៣ ទៅ!" ពួកគេត្រូវវា ពីកន្លែងចាប់ផ្តើម រហូតទៅដល់ទីបញ្ចប់រួចត្រឡប់ មកកន្លែងចាប់ផ្តើមវិញ។ ក្រុមណាដែលត្រូវមកដល់ទីវិញបានមុនគេក្រុមនោះជាអ្នកឈ្នះ។

៤. នៅពេលលេងល្បែងនេះចប់ គ្រូសូមពន្យល់កុមារថា ព្រះយេស៊ូវ គឺជាស្តេចរបស់យើង ហើយថាយើងត្រូវ បន្ទាបខ្លួនជានិច្ច នៅពេលដែលយើងមើលថែអ្នកដទៃ។

## ៨. ខគម្ពីរចងចាំ

**វិវរណៈ ១៩៖១៦** *" ទ្រង់មានព្រះនាមកត់នៅព្រះពស្ត្រ ហើយនៅព្រះឱរូទ្រង់ថា «ស្តេចលើអស់ទាំងស្តេច ជាព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់»"។*

## ៩. ហាត្ថកម្ម

សូមផាត់ព៌ណលើរូបភាព អាទិត្យស្លឹកចាក។

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

វាងាយស្រួលក្នុងការបង្ហាញអាកប្បកិរិយាមិនត្រេកអរអំពីជំនឿដែលអ្នកមិនសប្បាយចិត្តពំពោះព្រះយេស៊ូវ ប៉ុន្តែសាច់រឿងក្នុងខគម្ពីរថ្ងៃនេះគឺមានមនុស្សម្នាជាច្រើន បានលើកដំកើងដោយការបង្ហាញការថ្វាយបង្គំ ចំពោះទ្រង់ជាសាធារណៈយ៉ាងរំភើបចិត្ត។ តើអ្នកអាចធ្វើអ្វីបានដើម្បីបំបាត់ការត្រេកអរ? តើអ្នកនឹងបង្ហាញពីការថ្វាយបង្គំព្រះយេស៊ូវដោយរំភើបចិត្តនៅក្នុងសប្តាហ៍នេះ? សូមអធិដ្ឋានពីសកម្មភាពដែលអ្នកអាចធ្វើ ឬពាក្យសំដីដែលអ្នកអាចនិយាយនូវសប្តាហ៍នេះដើម្បីលើកដំកើងព្រះយេស៊ូវជាព្រះមេស៊ីដូចដែលអ្នកនឹងរៀបចំបង្រៀនដល់កុមារដែរ។

មនុស្សម្នារីករាយពេលដែលព្រះយេស៊ូវយាងចូលទីក្រុងយេរូសាឡឹម!



សូមសរសេរខគម្ពីរចងចាំៈ______________________________